ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# សេចក្តីជូនដំណឹង
# ស្តីពី
# ការជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យាដើម្បីចូលបម្រើការងារ នៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមជម្រាបជូនដំណឹង ដល់សាធារណជនឱ្យបានជ្រាបថា ក្រសួងសេដ្ឋកិច្ច-និងហិរញ្ញវត្ថុ ត្រូវការជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យាសរុបចំនួន ០៣ រូប មកបម្រើការងារពេញម៉ោងក្នុងតួនាទីជា បុគ្គលិកទំនាក់ទំនងសាធារណៈ (Public Relations Officer) ដែលត្រូវមានគុណវុឌ្ឍិ ដូចមានភ្ជាប់ក្នុងលក្ខខណ្ឌយោង។

បេក្ខជនដែលមានចំណាប់អារម្មណ៍ត្រូវចូលទៅកាន់ផតថល https://career.digitaleconomy.gov.kh/ រួចស្កេន QR Code ដែលមាននៅលើផតថលដោយប្រើប្រាស់កម្មវិធីទូរស័ព្ទ CamDigiKey ដើម្បីដាក់ពាក្យស្នើសុំបម្រើការងារ។ មានតែបេក្ខជនដែលជាប់ដំណាក់កាលសម្រាំងជ្រើសរើស (Shortlist) ប៉ុណ្ណោះ ដែលនឹងទទួលបានការទំនាក់ទំនងអញ្ជើញមកសម្ភាសន៍។

ការទទួលពាក្យចាប់ផ្តើមពីថ្ងៃជូនដំណឹងនេះរហូតដល់ ថ្ងៃទី៨ ខែមីនា ឆ្នាំ ២០២៤ វេលាម៉ោង ១៧:០០ នាទី។

ថ្ងៃពុធ ១២កើត ខែមាឃ ឆ្នាំ ថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ ២០២៤

សូមស្កេនដើម្បីទៅកាន់តំណ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# លក្ខខណ្ឌយោង
# ស្តីពី
# ការជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យាចំនួន ០៣ រូប
# តួនាទី បុគ្គលិកទំនាក់ទំនងសាធារណៈ ( Public Relations Officer )
# ដើម្បីចូលបម្រើការងារនៅ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

*ភារកិច្ច និង ការទទួលខុសត្រូវ៖*

- ប្រមូលព័ត៌មាន ឬទិន្នន័យពាក់ព័ន្ធនឹងសកម្មភាពរៀបចំ និង អនុវត្តគោលនយោបាយនៃការកសាង និង ការអភិវឌ្ឍសេដ្ឋកិច្ចធុរកិច្ច និង សង្គមឌីជីថលដើម្បីផលិត និង រៀបចំរចនាក្រាហ្វិក ផ្ទាំងរូបភាព វីដេអូគំនូរជីវចល ឬ វីដេអូខ្លី ដើម្បីផ្សព្វផ្សាយជាសាធារណៈ
- រៀបចំ និង គ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល
- ទំនាក់ទំនង និង សម្របសម្រួលការងារផ្ទៃក្នុងរបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល ឬ អង្គភាពពាក់ព័ន្ធ
- ពិនិត្យ រៀបចំ សម្របសម្រួល និង សហការការងារជាមួយអង្គភាពពាក់ព័ន្ធក្នុងការរៀបចំកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល សន្និសីទ ព្រឹត្តិការណ៍ចែករំលែកចំណេះដឹង និង យន្តការផ្សព្វផ្សាយនានា
- រៀបចំពិធីការ និង សម្របសម្រួលការងារទទួលភ្ញៀវជាតិ ឬអន្តរជាតិរបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថលដោយសហការជាមួយអង្គភាពពាក់ព័ន្ធ
- រៀបចំ និង បណ្តុះបណ្តាលបុគ្គលិក និងមន្ត្រីជំនាញពាក់ព័ន្ធតាមការចាំបាច់
- អនុវត្តភារកិច្ចការងារផ្សេងទៀតតាមការប្រគល់ជូនពីថ្នាក់ដឹកនាំ។

*បេក្ខជន ត្រូវមានគុណវុឌ្ឍិទូទៅដូចខាងក្រោម៖*

១. មានសញ្ញាបត្រកម្រិតបរិញ្ញាបត្រឡើងទៅលើជំនាញរដ្ឋបាលសាធារណៈ សេដ្ឋកិច្ច ហិរញ្ញវត្ថុ ទំនាក់ទំនងអន្តរជាតិ ឬសញ្ញាបត្រជំនាញប្រហាក់ប្រហែល

២. មានបទពិសោធន៍ទាក់ទងនឹងផ្នែកទំនាក់ទំនងសាធារណៈយ៉ាងតិច ១ ឆ្នាំ

៣. មានបទពិសោធន៍ក្នុងការផលិតវីដេអូ កែសម្រួល និងការសរសេរមាតិកា

៤. មានចំណេះដឹងប្រើប្រាស់កម្មវិធី Microsoft Office និង កម្មវិធីរចនាដូចជា Adobe Photoshop, Illustrator

៥. មានបទពិសោធន៍សម្របសម្រួលការងារ និងទំនាក់ទំនងជាមួយវិស័យរដ្ឋ វិស័យឯកជន ឬ ដៃគូអភិវឌ្ឍន៍

៦. មានចំណេះដឹងភាសាខ្មែរ និង ភាសាអង់គ្លេសច្បាស់លាស់ អាចនិយាយ សរសេរ និង ប្រើប្រាស់ជាផ្លូវការបាន

៧. មានបទពិសោធន៍សរសេរអត្ថបទខ្លីៗ សេចក្តីប្រកាសព័ត៌មាន ឬ អត្ថបទផ្លូវការនានា

៨. មានផ្នត់គំនិតលូតលាស់ក្នុងការបំពេញការងារប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និង បង្ហាញពីឆន្ទៈខ្ពស់

ក្នុងការរៀនសូត្រចំណេះដឹងថ្មី

៩ . មានគំនិតផ្តួចផ្តើមប្រកបដោយភាពច្នៃប្រឌិត សមត្ថភាពបំពេញដោយឯករាជ្យ និង ការងារជាក្រុមបានល្អ រួមទាំងមានជំនាញក្នុងការប្រាស្រ័យទំនាក់ទំនងល្អប្រសើរ

១០. មានអត្តចរិតស្លូតបូត ស្មោះត្រង់ អត់ធ្មត់ ឧស្សាហ៍ព្យាយាម និង យកចិត្តទុកដាក់បំពេញការងារ

១១. មានអាកប្បកិរិយាល្អ គោរពក្រមសីលធម៌វិជ្ជាជីវៈ និង ពុំមានជាប់ទោសពីបទឧក្រិដ្ឋ ឬ មជ្ឈិម

១២. មានឆន្ទៈខ្ពស់ចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការកសាង និង អភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល

១៣. មានចំណេះដឹងពាក់ព័ន្ធនឹងសេដ្ឋកិច្ច និងសង្គមឌីជីថល (ជាការប្រសើរ)។

*លក្ខខណ្ឌនៃការជ្រើសរើស៖*

- បេក្ខជនត្រូវចូលទៅកាន់ផតថល https://career.digitaleconomy.gov.kh/ រួចស្កេន QR Code ដែលមាននៅលើផតថលដោយប្រើប្រាស់កម្មវិធីទូរស័ព្ទ CamDigiKey ដើម្បីដាក់ពាក្យស្នើសុំបម្រើការងារ។
- បេក្ខជនត្រូវរៀបចំ និង ផ្ញើ Resume (max: ១ទំព័រ) និង Cover Letter (max: ១ទំព័រ) បង្ហាញពីគោលបំណងក្នុងការដាក់ពាក្យ បទពិសោធន៍ការងារពាក់ព័ន្ធដែលឆ្លើយតបទៅនឹងគុណវុឌ្ឍិខាងលើ។
- បេក្ខជន ឬ បេក្ខនារីដែលជាប់ដំណាក់កាលសម្រាំងជ្រើសរើស (Shortlist) តែប៉ុណ្ណោះដែលនឹងត្រូវអញ្ជើញមកសម្ភាសន៍ផ្ទាល់មាត់។

*ចាប់ផ្តើមទទួលពាក្យចាប់ពីថ្ងៃជូនដំណឹងរហូតដល់ថ្ងៃទី ៤ ខែមិនា ឆ្នាំ ២០២៤ វេលាម៉ោង ១៧:០០នាទី។*

ថ្ងៃពុធ ១២កើត ខែមាឃ ឆ្នាំ ថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ ២០២៤